# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ

## I. ស្ថានភាពភូមិសាស្ត្រ និងប្រជាពលរដ្ឋ

ខេត្តព្រះសីហនុស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា មានចម្ងាយប្រមាណ២៣០គីឡូម៉ែត្រ ពីរាជធានី ភ្នំពេញ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពត និងខេត្តកំពង់ស្ពឺ ខាងលិច និងខាងត្បូងជាប់ឈូងសមុទ្រថៃឡង់ ខាងជើងជាប់នឹងខេត្តកោះកុង ។ ខេត្តចែកចេញជា០១ក្រុង និង០៣ស្រុក មាន២២ឃុំ និង០៥សង្កាត់ មាន១១១ភូមិ។ មានឆ្នេរសមុទ្រលាតសន្ធឹងប្រវែង ១៧៥,៨៧ គីឡូម៉ែត្រ មានកោះចំនួន៣២កោះ ។ ផ្ទៃដីសរុប ២,៦៥៨.៩០ គីឡូម៉ែត្រការ៉េ ប្រជាពលរដ្ឋសរុប ៤៥,០៦៦គ្រួសារ មានប្រជាជនរស់នៅចំនួន ២១១,៥២៦នាក់ ស្រី ១០៧,០៨១នាក់ ។ ដង់ស៊ីតេប្រជាជន ៨៣នាក់ ក្នុង០១គីឡូម៉ែត្រការ៉េ ។ ប្រជាជនប្រមាណ ៣៣.៦០% មានមុខរបរពឹងផ្អែកលើវិស័យកសិកម្ម ក្រៅពីនោះមានមុខរបរផ្សេងៗទៀតដូចជា អាជីវកម្ម អ្នកជំនួញ សិប្បកម្ម និងនេសាទដែលជាមូលដ្ឋានសម្រាប់បង្កើតប្រាក់ចំណូល ។

## II. ស្ថានភាពរបស់មន្ទីរ

### 1. ការិយាល័យរដ្ឋបាល និងបុគ្គលិកៈ

- ចំនួនមន្ត្រីក្របខណ្ឌសរុប = ២១នាក់
- ប្រុស = ១៩នាក់
- ស្រី = ០២នាក់
- មន្ត្រីកម្មសិក្សា = ០៧នាក់
- អវត្តមាន = ០០នាក់
- បានរៀបចំរាល់ឯកសារចេញចូល ហើយបានទុកដាក់តាមក្រឹត្យក្រមនៃប្រព័ន្ធឯកសារ ។
- តាមដាន និងបន្តការអនុវត្តការចុះបញ្ជីវត្តមានមន្ត្រីរាជការ ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ស្របតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ៥៦ ។
- បានចូលរួមប្រជុំត្រួតពិនិត្យលើការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាតាមអង្គភាពចំណុះខេត្តព្រះសីហនុជាមួយក្រុមការងារក្រសួងមុខងារសាធារណៈ ។
- បានធ្វើរបាយការណ៍ ស្តីពីបច្ចុប្បន្នភាពនៃការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ របស់មន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ សម្រាប់ខែមករា កុម្ភៈ មីនា មេសា ឧសភា មិថុនា ឆ្នាំ ២០១៧ ។
- បានធ្វើរបាយការណ៍ ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ សម្រាប់ខែមករា កុម្ភៈ មីនា មេសា ឧសភា មិថុនា ឆ្នាំ ២០១៧ ។
- បានប្រជុំជាមួយក្រុមការងារមន្ទីរមុខងារសាធារណៈខេត្តព្រះសីហនុ ស្តីពីការត្រួតពិនិត្យមន្ត្រីក្របខណ្ឌឆ្នាំ ២០១៦ និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការស៊ីវិល នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ។

- បានចូលរួមប្រជុំកែសម្រួលលើតារាងពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងមុខតំណែងគ្រប់គ្រងដែលប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- បានទទួលលិខិតចូលចំនួន ២១៤លេខ និងបានចុះលេខលិខិតចេញចំនួន ២១៤លេខ ។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ:**

- បានចុះបញ្ជីចំណូលចំណាយទៅតាមប្រព័ន្ធការងារគណនេយ្យ និងបើកប្រាក់បៀវត្ស ប្រាក់បេសកកម្មជូនមន្ត្រីរាជការទាន់ពេលវេលា ។
- នៅថ្ងៃទី ១៧ ដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៧ មន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ បានធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការអនុលោមតាមបទបញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ។
- បានរៀបចំឯកសារសម្រាប់ការចុះធ្វើអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិ- ការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តរដ្ឋក្នុងការិយបរិច្ឆេទឆ្នាំ ២០១៦ និងបណ្តាឆ្នាំពាក់ព័ន្ធ ។
- បានរៀបចំឯកសារសម្រាប់ការចុះធ្វើអធិការកិច្ចរបស់សវនកម្មផ្ទៃក្នុង នៃក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការធ្វើសវនកម្មលើការងារគ្រប់គ្រងរដ្ឋបាល ថវិកាកម្មវិធី និងមិនមែនកម្មវិធី ឆ្នាំ ២០១៦-២០១៧ ។
- បានរៀបចំឯកសារសំរាប់ការចុះធ្វើអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ចំណូលសារពើពន្ធ-មិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការតព្វកិច្ចត្រូវបង់ចំណូលថវិការដ្ឋក្នុងការិយបរិច្ឆេទ ២០១៦ និងឆ្នាំពាក់ព័ន្ធ ។
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការរៀបចំផែនការថវិកាឆ្នាំ ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។
- បានចូលរួមវគ្គបណ្តុះបណ្តាល និងរិក្រឹតការស្តីពីវិធាន និងបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។
- បានរៀបចំឯកសារសម្រាប់ការចុះធ្វើអធិការកិច្ចរបស់អគ្គាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ លើការងារគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋការិបរច្ឆេទ ២០១៦ ។
- បានទៅទំនាក់ទំនងបើកថវិកាសម្រាប់ផ្គត់ផ្គង់សម្ភារៈសាងសង់បង្គន់អនាម័យឆ្នាំ ២០១៧ នៅរាជធានី ភ្នំពេញ ។

3. **ការិយាល័យផែនការ និងស្ថិតិ:**

- បានធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ប្រចាំត្រីមាសទី០១ និងប្រចាំត្រីមាសទី២របស់មន្ទីរដើម្បីផ្តល់ជូនសាលាខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទ ។
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការរៀបចំផែនការថវិកាឆ្នាំ ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

4. **ទំនាក់ទំនងសាធារណៈ**

- លោកប្រធានមន្ទីរ និងលោកអនុប្រធានមន្ទីរ ០១រូប បានចូលរួមប្រជុំ ស្តីពីការងារឥណទានជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទនាថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានការិយាល័យ០១រូប បានចូលរួមក្នុងកិច្ចប្រជុំដើម្បីត្រួតពិនិត្យលើរបាយការណ៍ ស្តីពីសំណើរសំនូមពរ និងកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកអនុប្រធានមន្ទីរ ០១រូប និងមន្ត្រីការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ០១រូប បានចូលរួមប្រជុំ ផ្សព្វផ្សាយស្តីពីការរៀបចំពិពណ៌នាមុខដំណែងសម្រាប់មន្ត្រីរាជការក្នុងរចនាសម្ពន្ធ័គ្រប់គ្រងរបស់ក្រសួងអភិវឌ្ឍន៍ជនបទដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០១៧ មន្ទីរបានរៀបចំប្រជុំអបអរសាទរទិវានារីអន្តរជាតិ ០៨ មីនា ២០១៧ ខួបទី ១០៦ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ។
- លោកអនុប្រធានមន្ទីរ ០១រូប បានចូលរួមកិច្ចប្រជុំពិនិត្យរបាយការណ៍ប្រចាំឆ្នាំ ២០១៦ របស់ក្រុមការងារចុះមូលដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទដើម្បីត្រួតពិនិត្យកម្មវិធីគោលនយោបាយនិងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ ០១រូប និងលោកប្រធានការិយាល័យ ០១រូប បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីអត្រាការប្រាក់ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានការិយាល័យ ០៣រូប បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំផែនការថវិកា សម្រាប់គាំទ្រសហគមន៍សន្សំប្រាក់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្នាក់ដឹកនាំមន្ទីរ ប្រធានការិយាល័យ និងមន្ត្រីកម្មសិក្សា សរុបចំនួន១៦រូប បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៧ នៅសាលសន្និសីទចតុមុខ ។
- លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ ០១រូប និងលោកប្រធានការិយាល័យ ០២រូប បានចូលរួមកិច្ចប្រជុំស្តីពីការងារគម្រោងឥណទានជនបទ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៧ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- លោកប្រធានមន្ទីរ និងប្រធានការិយាល័យ ០១រូប បានចូលរួមកិច្ចប្រជុំ ស្តីពីការឆ្លើយបំភ្លឺលើចំណុចខ្វះខាតដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរកឃើញក្នុងការធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៥ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

- លោកប្រធានមន្ទីរ បានចូលរួមជាកិត្តិយសក្នុងពិធីបើកជាផ្លូវការសន្និសីទ ស្តីពីទេសចរណ៍ និងទីក្រុងបេតិកភ័ណ្ឌ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ ដែលប្រព្រឹត្តទៅ នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំសណ្ឋាគារសុខាសៀមរាបរីហ្សតខេត្តសៀមរាប ។
- លោកអនុប្រធានមន្ទីរ ០១រូប បានចូលរួមប្រជុំចរចារថ្លៃលើគម្រោងការងារផ្គត់ផ្គង់សម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យដែលប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៧នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- លោកអនុប្រធានមន្ទីរ ០១រូប និងប្រធាន-អនុប្រធានការិយាល័យ ០២រូប បានចូលរួមប្រជុំកែសម្រួលលើតារាងពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការ ក្នុងមុខតំណែងគ្រប់គ្រង ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកប្រធានមន្ទីរ អនុប្រធានមន្ទីរ និងប្រធានការិយាល័យ បានចូលរួមប្រជុំជាមួយឯកឧត្តមអភិបាលខេត្តព្រះសីហនុ និងអង្គភាពផ្សេងៗបានចំនួន ៨០លើក ។

## III. ស្ថានភាពតាមវិស័យ

### 1. ការងារផ្លូវជនបទៈ

- នៅព្រឹកថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៧ **ឯកឧត្តមនាយឧត្តមសេនីយ៍ ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង **ឯកឧត្តម យន្ត មីន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធបើកការដ្ឋានស្ថាបនាផ្លូវបេតុង ០១ខ្សែ មានប្រវែង ៧,៣០០ម៉ែត្រ តភ្ជាប់ពីផ្លូវជាតិលេខ៤ ភូមិអូរចំណារ ឃុំអូរឧកញ៉ាហេង ឆ្លងកាត់ឃុំបឹងតាព្រហ្ម ទៅដល់ភូមិកោះខ្យង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយផ្លូវនេះបម្រើផលប្រយោជន៍ផ្ទាល់ដល់ប្រជាពលរដ្ឋនៅក្នុងភូមិសាស្រ្តខាងលើមានចំនួន ៤,៣៣៨គ្រួសារ ។
- ក្រុមការងារដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះធ្វើបច្ចុប្បន្នភាពលើខ្សែផ្លូវចំនួន ៥៤ខ្សែ ប្រវែង ១៤៣.៩៥០គីឡូម៉ែត្រ ស្ថិតនៅក្នុងស្រុកព្រៃនប់ និងស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។
- ចុះពិនិត្យជ្រើសរើស និងសិក្សាខ្សែផ្លូវសម្រាប់ថែទាំជាលក្ខណៈខួបចំនួន ០៤ខ្សែ ប្រវែង ១៤,២០០ម៉ែត្រ ស្ថិតនៅក្នុងស្រុកព្រៃនប់ និងស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។
- ចុះពិនិត្យ និងជ្រើសរើសខ្សែផ្លូវសម្រាប់ជួសជុលបន្ទាន់ចំនួន ០១ខ្សែ ប្រវែង ២,០០០ម៉ែត្រ ស្ថិតនៅក្នុងភូមិបឹងតាស្រី ឃុំបឹងតាព្រហ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- ចុះពិនិត្យខ្សែផ្លូវសម្រាប់ថែទាំប្រចាំចំនួន ០៤ខ្សែ ប្រវែង ៣១,៤០០ម៉ែត្រ ស្ថិតនៅស្រុកព្រៃនប់ និងស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។
- បានចុះពិនិត្យទីតាំងដើម្បីស្ថាបនាផ្លូវថ្មីចំនួន ០១ខ្សែ ប្រវែង ៤,៥០០ម៉ែត្រ ស្ថិតនៅក្នុងឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។
- បានចុះពិនិត្យការងារថែទាំផ្លូវជាលក្ខណៈខួប ក្នុងគម្រោងផែនការឆ្នាំ ២០១៧ ចំនួន ០៥ខ្សែ ប្រវែង ៦,៨០០ ម៉ែត្រ ស្ថិតនៅក្នុងឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

- បានចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវចំនួន ០១ខ្សែ ប្រវែង ២,៤០០ម៉ែត្រ ស្ថិតនៅក្នុងឃុំបឹងតា-ព្រហ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បន្តចុះពិនិត្យការងារថែទាំផ្លូវជាលក្ខណៈខួបក្នុងផែនការឆ្នាំ ២០១៧ ចំនួន ០៦ខ្សែ ប្រវែង ៧,៧០០ម៉ែត្រ ស្ថិតនៅក្នុងឃុំអូរឧកញ៉ាហេង និងឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បន្តចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវចំនួន ០១ខ្សែ ប្រវែង ២,៤០០ម៉ែត្រ ស្ថិតនៅក្នុងឃុំបឹង-តាព្រហ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

## 2. ការងារថែទាំសុខភាពជនបទៈ

- បានចុះពិនិត្យការសាងសង់បង្គន់អនាម័យ ដែលបានផ្តល់ជូនក្នុងឆ្នាំ ២០១៦ កន្លងមកក្នុងភូមិទាំង៨ នៃឃុំទឹកល្អក់ និងឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះសិក្សាស្ថានភាពភូមិដោយមានការចូលរួម (PVA) នៅឃុំសំរុង ឃុំអណ្តូងថ្ម និងឃុំអូរជ្រៅ ស្រុកព្រៃនប់ ដើម្បីផ្តល់សម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យនៅក្នុងផែនការឆ្នាំ ២០១៧ ។
- បានចូលរួមប្រជុំប្រចាំខែមករា កុម្ភៈ មីនា មេសា ឧសភា មិថុនា របស់គណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ក្រុងព្រះសីហនុ ។
- បានប្រជុំផ្សព្វផ្សាយ ស្តីពី "**របៀបនៃការផ្លាស់ប្តូរទម្លាប់ ការបន្ទោបង់ពាសវាលពាសកាល និងការលើកកម្ពស់អនាម័យនៅសហគមន៍**" នៅឃុំអូរជ្រៅ ស្រុកព្រៃនប់ដែលមានសមាសភាពចូលរួមពី សមាជិកក្រុមប្រឹក្សាឃុំ, អាជ្ញាធរភូមិ, ជនបង្គោល, គណៈកម្មាធិការទ្រទ្រង់ស្ត្រី និងកុមារ និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងៗទៀតក្នុងឃុំ សរុបចំនួន ៤៥រូប ។
- ផ្សព្វផ្សាយគោលការណ៍ណែនាំ "**កម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ**" ជូនដល់គណៈកម្មាធិការទទួលបន្ទុកអនាម័យស្រុក ក្រុមប្រឹក្សាឃុំ និងជនបង្គោលអនាម័យក្នុងភូមិ នៃឃុំអូរជ្រៅ ឃុំអណ្តូងថ្ម និងឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានសមាសភាពចូលរួមសរុបចំនួន ៤២នាក់ ស្រី ២៧នាក់ នៅទីតាំងសាលាបឋម-អនុវិទ្យាល័យសំរុង ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលផ្តោតសំខាន់លើការលើកកម្ពស់សុខភាពអនាម័យរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ តាមរយៈការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល ការបរិភោគទឹកដែលមានសុវត្ថិភាព និងការរស់នៅប្រកបដោយអនាម័យជានិច្ច ។
- បានប្រជុំផ្សព្វផ្សាយ ស្តីពី "**របៀបនៃការផ្លាស់ប្តូរទម្លាប់ ការបន្ទោបង់ពាសវាលពាសកាល និងការលើកកម្ពស់អនាម័យនៅក្នុងសហគមន៍** " នៅឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានអ្នកចូលរួមចំនួន ៥១នាក់ (ស្រី ២១នាក់) ។
- បានចូលរួមវគ្គផ្សព្វផ្សាយពី "**គោលការណ៍ណែនាំកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀន និង សហគមន៍** " ជាមួយនាយកដ្ឋានថែទាំសុខភាពជនបទ នៅឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ដែលមានអ្នកចូលរួមចំនួន ៤៧នាក់ (ស្រី ១៧នាក់) ។
- បានចុះពិនិត្យទីតាំងសម្រាប់សាងសង់បង្គន់អនាម័យ និងផ្សព្វផ្សាយអំពីរបៀបនៃការសាងសង់បង្គន់អនាម័យតាមបច្ចេកទេសត្រឹមត្រូវ នៅតំបន់ចៃឆ្កែ ភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

## 3. ការងារផ្គត់ផ្គង់ទឹកជនបទ:

- បានចុះសិក្សាទីតាំង សម្រាប់ធ្វើការសាងសង់អណ្តូងស្នប់ (Afridew)ថ្មី ចំនួន ០៦អណ្តូង និងជួសជុលអណ្តូងស្នប់ ០៥អណ្តូង ស្ថិតនៅឃុំទឹកល្អក់ ឃុំទឹកថ្លា និងឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះសិក្សាទីតាំងសាងសង់អណ្តូងលូថ្មីចំនួន ០៨អណ្តូង នៅឃុំទួលទទឹង និងឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះពិនិត្យទីតាំងដែលមានអណ្តូងស្នប់ខូចប្រើប្រាស់លែងបាន សម្រាប់ធ្វើការជួសជុលនាពេលខាងមុខមានចំនួន ១០អណ្តូង ដែលមានទីតាំងស្ថិតនៅឃុំកំពង់សីលា ០៥អណ្តូង ឃុំអូរបាក់រទេះ ០៣អណ្តូង និងឃុំស្ទឹងឆាយ ០២អណ្តូង ។
- បានចុះត្រួតពិនិត្យទីតាំងដែលមានអណ្តូងស្នប់ខូចប្រើប្រាស់លែងបាន សម្រាប់ធ្វើការជួសជុលនាពេលខាងមុខមានចំនួន ៣០អណ្តូងដែលមានទីតាំងស្ថិតនៅឃុំបឹងតាព្រហ្ម ឃុំអូរជ្រៅ ឃុំអូរឧកញ៉ាហេង និងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានរៀបចំឯកសារ ស្តីពីទីតាំងលំអិតអណ្តូងស្នប់ Afredew មានចំនួន ៣០អណ្តូង ស្ថិតក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ធ្វើការជួសជុល ក្នុងគម្រោងផែនការឆ្នាំ ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។
- បានចុះជួសជុលអណ្តូងស្នប់ Afredev បានចំនួន ០៥អណ្តូង ដែលមានទីតាំងស្ថិតនៅ ឃុំរាម ចំនួន ០៣អណ្តូង និងឃុំអូរឧកញ៉ាហេង ចំនួន ០២អណ្តូង នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

## 4. ការងារបណ្តុះបណ្តាល និងស្រាវជ្រាវ:

- លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានការិយាល័យ ០១រូប បានចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងារឥណទានឆ្នាំ ២០១៦ និងទិសដៅការងារឆ្នាំ ២០១៧ នាថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្តមណ្ឌលគីរី ។
- ប្រធានការិយាល័យ ០១រូប បានចូលរួមវគ្គបណ្តុះបណ្តាលវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ នៅសាលាភូមិន្ទរដ្ឋបាល ។
- អនុប្រធានមន្ទីរ ០១រូប ប្រធានការិយាល័យ ០៣រូប និងមន្ត្រីកម្មសិក្សា ០១រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រសហគមន៍សន្សំប្រាក់ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ។
- លោកអនុប្រធានមន្ទីរ ០១រូប ប្រធាន-អនុប្រធានការិយាល័យ ០៣រូប និងមន្ត្រីកម្មសិក្សា ០២រូប បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការរៀបចំផែនការថវិកាឆ្នាំ ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ។
- លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានការិយាល័យ ០១រូប បានចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រឹតការ ស្តីពីវិធាន និងបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ នៅសាលប្រជុំសណ្ឋាគារភ្នំពេញរាជធានីភ្នំពេញ។
- លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានប្រធានការិយាល័យ ០១រូប បានចូលរួមសិក្ខាសាលា ស្តីពីតម្រូវការវគ្គបណ្តុះបណ្តាលតាមអង្គភាពក្រោមឱវាទក្រសួង ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ដល់ ២៤ ខែឧសភា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

- លោកប្រធានមន្ទីរ បានចូលរួមសិក្ខាសាលា ស្តីពីការចែករំលែកលទ្ធផល និងការអនុវត្តន៍ល្អរបស់គម្រោងបង្កើនប្រាក់ចំណូល និងអាហារូបត្ថម្ភតាមរយៈការពង្រឹងសិទ្ធិជាម្ចាស់ដល់សហគមន៍ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំសណ្ឋាគារកំបូឌីយ៉ាណារាជធានីភ្នំពេញ ។
- លោកប្រធានមន្ទីរ លោកប្រធានការិយាល័យ ០២រូប និងមន្ត្រី ០១រូប បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំនីតិវិធីគាំទ្រសហគមន៍សន្សំប្រាក់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ ០១រូប បានចូលរួមសិក្ខាសាលាតម្រង់ទិស ស្តីពីការរៀបចំផែនការ និងមុខងារនៃក្រុមការងារបច្ចេកទេសផ្គត់ផ្គង់ទឹកស្អាត ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

## 5. ការងារអភិវឌ្ឍន៍សហគមន៍:

- បានចុះពិនិត្យសមាសភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិមួយចំនួន ដើម្បីត្រៀមបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។
- បានចុះតាមដាន និងពិនិត្យសមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិមួយចំនួន និងពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅថ្ងៃទី ០៩-១០ ខែមីនា ឆ្នាំ ២០១៧ ។
- បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)មានសមាជិកចូលរួមមានចំនួន ៤៥នាក់ នៅឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានរៀបចំឯកសារសម្រាប់ការបើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលមានសមាជិកជា(គ.អ.ភ) ចូលរួមមានចំនួន ៤៥នាក់ នៅឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានជីកស្រះចិញ្ចឹមត្រីលក្ខណៈគ្រួសារចំនួន ០៥ស្រះ ដែលមានទទឹង៥ម៉ែត្រ x បណ្តោយ៦ម៉ែត្រ x ជម្រៅ២,៥ម៉ែត្រ ជូនប្រជាពលរដ្ឋចំនួន ០៥គ្រួសារ នៅភូមិស្រែចាមក្រោម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តដល់គ្រួសារសហគមន៍បានចំនួន ០៤វគ្គ នៅភូមិដូនលយ ភូមិបឹងតាព្រហ្ម ភូមិស្រែចាមលើ និងភូមិស្រែចាមក្រោម នៃឃុំបឹងតាព្រហ្ម និងឃុំអូរជ្រៅ ស្រុកព្រៃនប់ ដែលមានអ្នកចូលរួមសរុបចំនួន ៨៤នាក់ (ស្រី ៥១នាក់) ។
- បានចុះចែកពូជឈើហូបផ្លែចំនួន ៤០០ដើម ដល់ប្រជាពលរដ្ឋចំនួន ៧៥គ្រួសារ នៅភូមិស្រែចាម-ក្រោម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះចែកពូជមាន់ចំនួន ១៦០ក្បាល ដល់ប្រជាពលរដ្ឋចំនួន ៣២គ្រួសារ នៅភូមិស្រែចាមក្រោម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- បានចុះចែកពូជត្រី ចំនួន ១,៥០០ក្បាល ដល់ប្រជាពលរដ្ឋចំនួន ០៥គ្រួសារ នៅភូមិស្រែចាមក្រោម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

6. **ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ:**

- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលការប្រាក់ក្នុងកម្ចីឥណទានប្រចាំខែមករា ពីប្រជាពលរដ្ឋចំនួន ២៦គ្រួសារ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- ផ្តល់ប្រាក់កម្ចីដល់ក្រុមថ្មី ០១ក្រុមបន្ថែមទៀត មានសមាជិកចំនួន ០៤នាក់ជាស្ត្រី នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលការប្រាក់ក្នុងកម្ចីឥណទានប្រចាំខែកុម្ភៈ ពីប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ២៩នាក់ ប្រុស ០១នាក់ នៅភូមិស្រែចាមលើក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលការប្រាក់ក្នុងកម្ចីឥណទានប្រចាំខែមីនា ពីប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ២៩នាក់ ប្រុស ០១នាក់ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលការប្រាក់ក្នុងកម្ចីឥណទានប្រចាំខែមេសា ពីប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ២៩នាក់ ប្រុស ០១នាក់ និងបានប្រជុំជាមួយក្រុមប្រឹក្សាឃុំពាក់ព័ន្ធជាមួយការងារឥណទាន ជាមួយអតិថិជនដែលបានបង់ការប្រាក់យឺតយ៉ាវ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលប្រាក់ក្នុងកម្ចីឥណទាន ដែលនៅសេសសល់ក្នុងខែឧសភា ពីប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ១៨នាក់ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។
- មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានចុះប្រមូលប្រាក់ក្នុងកម្ចីឥណទាន ដែលនៅសេសសល់ក្នុងខែមិថុនា ពីប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ១៣នាក់ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងបានអញ្ជើញអតិថិជនដែលមិនទាន់បានបង់ប្រាក់មកប្រជុំនៅសាលាឃុំ ដើម្បីធ្វើកិច្ចសន្យា ។
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំនីតិវិធីគាំទ្រសហគមន៍សន្សំប្រាក់ ដែលប្រព្រឹត្តទៅ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

7. **ការងារអភិវឌ្ឍន៍ជនជាតិភាគតិច:**

- មន្ត្រីការិយាល័យជនជាតិភាគតិចបានចុះជួយធ្វើការងារជាមួយការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ក្នុងការចុះប្រមូលការប្រាក់ក្នុងកម្ចីឥណទានប្រចាំខែមេសា របស់ប្រជាពលរដ្ឋចំនួន ០៥ក្រុម មានសមាជិក ២៩នាក់ ប្រុស ០១នាក់ និងបានប្រជុំជាមួយក្រុមប្រឹក្សាឃុំពាក់ពន្ធ័ ជាមួយការងារឥណទាន ជាមួយអតិថិជនដែលបានបង់ការប្រាក់យឺតយ៉ាវ នៅភូមិស្រែចាមលើ ក្នុងឃុំអូរជ្រៅ នៃស្រុកព្រៃនប់ ។
- មន្ត្រីការិយាល័យជនជាតិភាគតិច បានចុះជួយធ្វើការងារជាមួយការិយាល័យផ្លូវជនបទ ក្នុងការចុះពិនិត្យការងារថែទាំផ្លូវជាលក្ខណៈខួប ក្នុងគម្រោងផែនការឆ្នាំ ២០១៧ ចំនួន ០៥ខ្សែ ប្រវែង ៦,៨០០ម៉ែត្រ ស្ថិតនៅក្នុងឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំនីតិវិធីគាំទ្រសហគមន៍សន្សំប្រាក់ ដែលប្រព្រឹត្តទៅ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៧ នៅសាលប្រជុំទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

## IV. **សន្និដ្ឋាន**

ការងារគ្រប់ផ្នែករបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដែលសម្រេចកន្លងមកនេះគឺពិតជាបានមកពីការខិតខំយកចិត្តទុកដាក់បំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ របស់មន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងក្រោមការដឹកនាំណែនាំពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ពិសេស **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ព្រមទាំងមានការសហការពីអាជ្ញាធរមូលដ្ឋាន និងការចូលរួមចំណែកពីមន្ទីរស្ថាប័នពាក់ព័ន្ធនានាផងនោះឃើញថា ទោះបីកន្លងមកមានជួបការលំបាកយ៉ាងណាក៏ដោយ ក៏មកដល់បច្ចុប្បន្ននេះមន្ទីរមានមោទនភាពយ៉ាងខ្លាំង ដោយមានការគាំទ្រទាំងស្មារតី ក៏ដូចជាថវិកា និងសម្ភារៈពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាកត្តាមួយយ៉ាងសំខាន់ធ្វើឲ្យមន្ទីរអភិវឌ្ឍន៍ជនបទមានជំហរយ៉ាងរឹងមាំ ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញលើកកំពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលដៅ **ជាយុទ្ធសាស្ត្រដែលរាជរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ** បានដាក់ចុះ ។

**ប្រធានមន្ទីរ**